ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៣៦០
ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១
សាលដីកា
លេខ ១៤៧ "V"
ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ជាប្រធាន

២.ឯកឧត្តម [redacted] ជាចៅក្រម

៣.ឯកឧត្តម [redacted] ជាចៅក្រមរបាយការណ៍

៤.ឯកឧត្តម [redacted] ជាចៅក្រម

៥.ឯកឧត្តម [redacted] ជាចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោកស្រី ម៉ុម សុខវល័ក្ខ

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣៣៣ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]សុវណ្ណ ឈ្មោះ [redacted]រៈ និងឈ្មោះ[redacted]រដ្ឋា ដែលប្តឹងមិនសុខចិត្តចំពោះសាលដីកាលេខ ៦៥ ក្រII "ន" ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

**ជនជាប់ចោទ (អ្នកប្តឹងសាទុក្ខ)**

១-ឈ្មោះ [redacted] រដ្ឋា ហៅ ថា ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិសែនសុខ សង្កាត់ ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃុំខ្លួន[redacted] ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥២៣១ "អ" ដ.ឃ.ដ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២១។





Scanned with CamScanner

២-ឈ្មោះ [redacted]ៈ ហៅ រៈ ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិស្ពៃ ឃុំគងជ័យ ស្រុកអូររាំងឪ ខេត្តកំពង់ចាម មានទីលំនៅមុនពេលឃុំខ្លួនស្ថ[redacted]រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted]រ" នៅលើវ ទោសពីមុនគ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥២៣២ "អ" ដ.ឃ.ដ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩។

**ជាប់ចោទពីបទ** លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្ដីការត្រួតពិនិត្យគ្រឿងញៀន។

-មានលោក [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិ

៣-ឈ្មោះ [redacted] សុវណ្ណ ហៅ ហ៊្គិច ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ មានទីលំនៅមុនពេល[redacted] ភូមិសែនសុខទី៦ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ[redacted] "រ" ។ ទោសពីមុនគ្មាន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៥១៣៩ "ច១" ដ.ឃ.ដ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩។

៤-ឈ្មោ[redacted]ហេង ហៅ ស្រីហេង ភេទប្រុស អាយុ ២៦ឆ្នាំ។

៥-ឈ្មោះ [redacted] ភា ហៅ ភា ភេទប្រុស អាយុ ២២ឆ្នាំ។

៦-ឈ្មោះ [redacted] លីហ៊ាង ហៅ ហ៊ាង ភេទប្រុស អាយុ ២២ឆ្នាំ។

៧-ឈ្មោះ [redacted] ស្វិត ហៅ ស្វិត ភេទប្រុស អាយុ ២៣ឆ្នាំ។

៨-ឈ្មោះ [redacted] សុភក្តី ហៅ ធូ ភេទប្រុស អាយុ ២៣ឆ្នាំ។

៩-ឈ្មោះ [redacted] ផានិត ហៅ ក្និត ភេទប្រុស កើតឆ្នាំ១៩៩៦។

**ជាប់ចោទពីបទ** លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-មានលោក[redacted] ធុនណា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សុវណ្ណ

**ដើមបណ្ដឹងរដ្ឋប្បវេណី**

-ឈ្មោះ[redacted]ស៊ីណាត ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅបន្ទប់ជួល ផ្លូវបេតុង ភូមិរកា ឃុំឬស្សីស្រុក ស្រុកអង្គស្នួល ខេត្តកណ្ដាល។

Scanned with CamScanner

អំពីអង្គហេតុ ៖

កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង ០៤ និង ០០នាទីទៀបភ្លឺ នៅចំណុចមុខសាលាបឋមសិក្សាត្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានករណី លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា មួយបានកើតឡើងដែលបង្កដោយជនជាប់ចោទចំនួន ១០ នាក់ ឈ្មោះ [redacted] វឌ្ឍា ហៅ ថា ភេទប្រុស អាយុ ១៨ឆ្នាំ ឈ្មោះ [redacted] រះ ហៅ រះ ភេទប្រុស អាយុ ២៨ឆ្នាំ ឈ្មោះ [redacted] សុភា ហៅ ភា ភេទប្រុស អាយុ ២២ឆ្នាំ ឈ្មោះ [redacted] ស្វិត ហៅ ស្វិត ភេទប្រុស អាយុ ២៣ឆ្នាំ ឈ្មោះ [redacted] ប៊ីហ៊ាង ភេទប្រុស អាយុ ២២ឆ្នាំ ឈ្មោះ [redacted] សុភក្តី ហៅ ធូ ភេទប្រុស អាយុ ២៣ឆ្នាំ ឈ្មោះ [redacted] សុវណ្ណ ហៅ ហ៊្គិច ភេទប្រុស អាយុ ២២ឆ្នាំ ឈ្មោះ [redacted] ហេង ហៅ ស្រីហេង ភេទប្រុស អាយុ ២៦ឆ្នាំ ឈ្មោះ [redacted] ផានិត ហៅ ក្និត ភេទប្រុស អាយុ ២៤ឆ្នាំ និងឈ្មោះ ហុង ភេទប្រុស អាយុប្រហែល ១៧ឆ្នាំ បានធ្វើសកម្មភាពយកកាំបិតផ្គាក់ប្រវែងប្រហែលកន្លះម៉ែត្រ កាប់មកលើជនរងគ្រោះឈ្មោះ [redacted] ស៊ីណាត ភេទប្រុស អាយុ ៣១ឆ្នាំ ។ ដោយនៅមុនពេលកើតហេតុជនរងគ្រោះជិះម៉ូតូម៉ាកសេ ១២៥ ស៊េរីឆ្នាំ២០១៧ ពណ៌ខ្មៅ ពាក់ស្លាកលេខ 1W-0477 លេខតួម៉ាស៊ីន ៩៧៧៩៦៣៥ ធ្វើដំណើរតាមបណ្តោយផ្លូវទំនប់កប់ស្រូវ (មហាវិថីវិមានឈ្នះ១) ទិសដៅពីលិចទៅកើតមកដល់ចំណុចកើតហេតុខាងលើ ពេលនោះជនជាប់ចោទឈ្មោះ [redacted] វឌ្ឍា ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] រះ ភេទប្រុស អាយុ ២៨ឆ្នាំ និងបក្ខពួកចំនួន ០៨នាក់ទៀត ឈ្មោះខាងលើបាន ឃើញជនរងគ្រោះជិះម៉ូតូតែម្នាក់ឯង ភ្លាមនោះជនជាប់ចោទឈ្មោះ [redacted] ហេង បានបន្ថែមល្បឿនម៉ូតូបើកទៅអែបទន្ទឹមម៉ូតូរបស់ជនរងគ្រោះ ហើយជនជាប់ចោទឈ្មោះ [redacted] សុភា បានលើកកាំបិតផ្គាក់កាប់មកលើជនរងគ្រោះពីក្រោយបណ្តាលឱ្យជនរងគ្រោះរបួសស្រាល មានស្នាមដាច់ ឆ្អូតចំនួន០២កន្លែងនៅលើខ្នង រួចជនរងគ្រោះបានដួលម៉ូតូ ហើយក៏ស្ទុះងើបរត់គេចខ្លួន ចំណែកឯបក្ខពួកបានជិះម៉ូតូបិទគូថ ហើយក៏គេចខ្លួនបាត់តែម្តង។ បន្ទាប់ពីកើតហេតុរួចមកជនរងគ្រោះក៏បានដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលឃ្មួញ ។ លុះដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ២២ និង ៣០ នាទី សមត្ថកិច្ចបានធ្វើការស្រាវជ្រាវរួចឃាត់ខ្លួនបានជនជាប់ចោទចំនួន ០២នាក់ ឈ្មោះ [redacted] រះ ភេទប្រុស អាយុ ២៨ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] វឌ្ឍា ភេទប្រុស អាយុ ១៨ឆ្នាំ យកមកអធិការដ្ឋាននគរបាលខណ្ឌសែនសុខ ដើម្បីធ្វើការសាកសួរ និងបានធ្វើតេស្តស្វែងរកសារធាតុញៀន ជាលទ្ធផលវិជ្ជមាន ទើបសមត្ថកិច្ចបញ្ជូនជនជាប់ចោទទាំងពីរនាក់មកតុលាការដើម្បីចាត់ការតាមនីតិវិធី ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១២៧៩ "ច១" ក្រ១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

៥.១.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ហ៊្គិច ភេទប្រុស អាយុ ២២ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៥ (ប្រាំ)ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ តាមមាត្រា ៣៥០ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ៖

Scanned with CamScanner

៥.២.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted] រដ្ឋា ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ[redacted]ៈ ភេទប្រុស អាយុ២៨ ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៥ (ប្រាំ)ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្ត អំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តទៅចំណុចមុខសាលាបឋមសិក្សាត្រពាំងវាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងវាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿង ញៀន ។

៥.៣.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]លីហ៊ាង ហៅ ហ៊ាង ភេទប្រុស អាយុ ២២ឆ្នាំ ដាក់ពន្ធនាគារ កំណត់រយៈពេល ០៣(បី)ឆ្នាំ តែព្យួរទោសធម្មតា ពីបទ លួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើ ហិង្សា ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងវាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងវាំង សង្កាត់ឃ្មួញ ខណ្ឌ សែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៣៥៣ និងមាត្រា ៧៥៧ នៃក្រមព្រហ្មទណ្ឌ។

៥.៤.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]ហេង ហៅ ស្រីហេង ភេទប្រុស អាយុ ២៦ឆ្នាំ ឈ្មោះ[redacted]សុភា ហៅ ភា ភេទប្រុស អាយុ ២២ឆ្នាំ, ឈ្មោះ[redacted] ស្ទិត ហៅ ស្ទិត ភេទប្រុស អាយុ ២៣ឆ្នាំ, ឈ្មោះ [redacted]សុភក្តី ហៅ ធូ ភេទប្រុស អាយុ ២៣ឆ្នាំ ,ឈ្មោះ[redacted]ផានិត ហៅ ក្និត ភេទប្រុស អាយុ ២៣ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ កំណត់រយៈពេល ០៦ (ប្រាំមួយ)ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅ ចំណុចសាលាបឋមសិក្សាត្រពាំងវាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងវាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានី ភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៥. ៥.បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ[redacted] ហេង ហៅ ស្រីហេង, ឈ្មោះ [redacted] សុភា ហៅ ភា ឈ្មោះ[redacted] ស្ទិត ហៅ ស្ទិត, ឈ្មោះ [redacted] សុភក្តី ហៅ ធូ, ឈ្មោះ [redacted] ផានិត ហៅ ក្និត តាមមាត្រា ៣៥៣ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ។

៥.៦.វត្ថុចាប់យកដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១៥៣០ រ.វ.ត ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ រួមមាន៖ ទូរស័ព្ទដៃចំនួនមួយគ្រឿងម៉ាក OPPO ពណ៌ទឹកមាស (មិនដំណើរការ)។ ម៉ូតូមួយគ្រឿង ម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១១ ពាក់ស្លាកលេខភ្នំពេញ 1BA-6484 (មិនប្រក្រតី) សម្រេចប្រគល់ ឱ្យម្ចាស់ដើមវិញ។

៥.៧.ពិរុទ្ធជនឈ្មោះ[redacted] រដ្ឋា, ឈ្មោះ[redacted]ៈ ,ឈ្មោះ[redacted] សុវណ្ណ ហៅ ហ៊ុច មានសិទ្ធិប្តឹងឧទ្ធរណ៍តាម ច្បាប់កំណត់។ ជនជាប់ចោទឈ្មោះ [redacted] ហេង ហៅ ស្រីហេង, ឈ្មោះ [redacted] សុភា ហៅ ភា, ឈ្មោះ [redacted] លីហ៊ាង ហៅ ហ៊ាង, ឈ្មោះ [redacted] ស្ទិត ហៅ ស្ទិត ឈ្មោះ [redacted] សុភក្តី ហៅ ធូ ,ឈ្មោះ [redacted] ផានិត ហៅ ក្និត និងដើម បណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ស៊ីណាត មានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] រដ្ឋា, ឈ្មោះ [redacted] រះ ,ឈ្មោះ[redacted] សុវណ្ណ ហៅ ហ្គិច កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]ហេង ហៅ ស្រីហេង, ឈ្មោះ [redacted] សុភា ហៅ ភា, ឈ្មោះ[redacted] លីហ៊ាង ហៅ ហ៊ាង, ឈ្មោះ[redacted] ស្ថិត ហៅ ស្ថិត, ឈ្មោះ [redacted] សុភក្តិ ហៅ ធូ, ឈ្មោះ [redacted]ជានិត ហៅ ក្និត និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាត ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១១៧៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ[redacted] រដ្ឋា ដែលប្តឹងមិនសុខចិត្តនិងសាលក្រមព្រហ្មទណ្ឌលេខ ១២៧៩ “ចរ” ក្រ១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១១៧៧ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ ហ្គួត សុវណ្ណ ដែលប្តឹងមិនសុខចិត្តនិងសាលក្រមព្រហ្មទណ្ឌលេខ ១២៧៩ “ចរ” ក្រ១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១១៨២ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ[redacted]រះ ដែលប្តឹងមិនសុខចិត្តនិងសាលក្រមព្រហ្មទណ្ឌលេខ ១២៧៩ “ចរ” ក្រ១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-សាលាឧទ្ធរណ៍បានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៦៥ ក្រII “ន” ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ១១៧៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ[redacted]រដ្ឋា និងបណ្តឹងឧទ្ធរណ៍លេខ ១១៧៧ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] សុវណ្ណ និងបណ្តឹងឧទ្ធរណ៍លេខ ១១៨២ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ[redacted]រះ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១២៧៩ "ចរ" ក្រ១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

សាលដីកានេះបានជំនុំជម្រះកាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ឈ្មោះ[redacted] រះ និងឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាត និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៣៣៣ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ឈ្មោះ[redacted] រដ្ឋា និងឈ្មោះ[redacted]រះ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៦៥ ក្រ II “ន” ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។



Scanned with CamScanner

## នាពេលសវនាការ

-ចៅក្រុមបានអានរបាយការណ៍។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្ដីសន្និដ្ឋានថា៖ យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted]រៈ និងឈ្មោះ [redacted] វដ្ឋា បានលើកឡើងនៅក្នុងសារណារបស់ខ្លួនថា ខ្លួនប្ដឹងសាទុក្ខមកនេះ ដោយសារសាលាឧទ្ធរណ៍ផ្ដន្ទាទោសខ្លួនធ្ងន់ធ្ងន់ពេក។ ជនជាប់ចោទបានសារភាពទទួលស្គាល់នូវការប្រព្រឹត្តរបស់ខ្លួនហើយ ជាគោលការណ៍ អង្គហេតុដែលបានចោទប្រកាន់ បានចូលជាស្ថាពរហើយ នៅតែទណ្ឌកម្មតែប៉ុណ្ណោះដែលក្រុមប្រឹក្សាត្រូវពិចារណា។

-យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ហ៊ិច បានឆ្លើយបដិសេធថា ខ្លួនពុំបានចូលរួមប្រព្រឹត្តនោះទេ។

-យល់ឃើញថា បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] រះ និងឈ្មោះ [redacted] វដ្ឋា ពុំមានមូលហេតុណាមួយដូចមានចែងនៅក្នុងមាត្រា ៤១៩ ឡើយ។ ឯការផ្ដន្ទាទោសទោសលើជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ស្ថិតនៅក្នុងលក្ខណៈវិមតិសង្ស័យនៅឡើយ។

### តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖

-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៦៥ ក្រ II "ន" ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការ លើកលែងតែចំណុចផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted]សុវណ្ណ មហាអយ្យការសូមទុកជូនក្រុមប្រឹក្សា សម្រេចតាមច្បាប់។

+លោក [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វដ្ឋា និងឈ្មោះ [redacted] រៈ ធ្វើសេចក្ដីសន្និដ្ឋានថា៖ នៅក្នុងសំណុំរឿងនេះ តាមអង្គហេតុ កំណត់ហេតុប៉ូលីស សាលក្រម សាលដីកា ជនជាប់ចោទទាំងពីរនាក់ គាត់ហាក់ពុំបានដឹងពីអំពើលួចទេ របៀបការចូលរួមដោយចៃដន្យក្នុងក្រុម ហើយឈ្មោះ ភា ជាអ្នកកាប់ទៅលើជនរងគ្រោះ ហើយពុំមានភាពធ្ងន់ធ្ងរអ្វីទេ។ កូនក្ដីខ្លួនពុំបានចូលរួមក្នុងទម្រង់១ ដែលនាំឱ្យគាត់មានការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ មានន័យថា បទល្មើសព្រហ្មទណ្ឌបានកើតឡើងពិតមែន ប៉ុន្តែកូនក្ដីខ្លួនពុំបានប្រព្រឹត្តទេ ។ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនៅតុលាការសាលាដំបូង និងសាលាឧទ្ធរណ៍ បែរជា ទទួលថាបានប្រព្រឹត្តទៅវិញ នេះជាបញ្ហា ។ ដូច្នេះខ្លួនពុំអាចធ្វើសេចក្ដីថ្លែងការណ៍ផ្ទុយនិងការស្នើរសុំទេ ប៉ុន្តែសំណូមពរធ្វើសេចក្ដីសន្និដ្ឋានពាក់ព័ន្ធជាមួយទោសនាពេលនេះ ឯកឧត្តមប្រធាននៅសាលាឧទ្ធរណ៍បានប្ដឹងឱ្យមានការបន្ធូរបន្ថយទោស ដោយសារសាលាដំបូងបានដាក់ទោសធ្ងន់ធ្ងរ ចំនួន ៥ឆ្នាំ ក្នុងម្នាក់ៗ ប៉ុន្តែនៅក្នុងសំអាងហេតុសាលាឧទ្ធរណ៍ពុំបាននិយាយពីកត្តាសម្រាលទេ ។ តាមមាត្រា ២៤ ចែងពីគោលការណ៍ឯកត្តកម្មនៃទោស មាត្រា ៩៣ ចែងពីស្ថានសម្រាល ហើយមាត្រា ៩៦ ចែពីស្ថានទម្ងន់។ កូនក្ដីខ្លួនទាំង ០២នាក់ ចេញពីកន្លែងកំសាន្ត ហើយក្រុមគាត់ជាអ្នកប្រព្រឹត្ត គាត់គ្រាន់តែឈរមើល។

សំណូមពរ ឯកឧត្តមប្រធានក្រុមប្រឹក្សា សម្រេចប្រសិនបើមានការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ គឺសូមឱ្យមានការបញ្ជូនទៅឱ្យបានលឿន ជៀសវាងដល់ថ្ងៃដែលជនជាប់ចោទចេញពីពន្ធនាគារ។



Scanned with CamScanner

+លោក [redacted] ធុនណា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ធ្វើសេចក្តីសន្និដ្ឋានថា៖ អង្គហេតុកើតមានឡើងនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ នៅមុខសាលាបឋមសិក្សាត្រពាំងរាំង ជិតវិមានឈ្នះៗ។ ដូចតំណាងមហាអយ្យការសាលាឧទ្ធរណ៍ភ្នំពេញ បានធ្វើសេចក្តីសន្និដ្ឋាន នៅក្នុងសាលដីកាលេខ ៦៥ ក្រ II "ន" ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ថា ឈ្មោះ [redacted] សុវណ្ណ ត្រូវបានចាប់ខ្លួនតាមអំណាចសាលក្រមទេ ដោយចោទប្រកាន់ពីបទឧក្រិដ្ឋ ដោយពុំបានបំពេញនីតិវិធីនៃកិច្ចស៊ើបសួរបានត្រឹមត្រូវទេ ពុំមានចម្លើយដាក់បន្ទុកកូនក្តីខ្លួនទេ ។ តាមចម្លើយឈ្មោះ [redacted] រដ្ឋា និងឈ្មោះ [redacted] រះ នៅក្នុងអង្គហេតុជនជាប់ចោទពីរនាក់នេះ ជាជនដែលដែលចាប់បានជាក់ស្តែងហើយឃុំខ្លួន ដោយឡែកកូនក្តីខ្លួនឈ្មោះ [redacted] សុវណ្ណ ត្រូវបានចាប់ខ្លួនតាមអំណាចសាលក្រមនោះទេ។ ហើយឈ្មោះ [redacted] រះ និង [redacted] រដ្ឋា បានឆ្លើយនៅសាលាដំបូងថា កូនក្តីខ្លួនឈ្មោះ [redacted] សុវណ្ណ អត់មានពាក់ព័ន្ធក្នុងរឿងនេះទេ។ តាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ គឺវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទជាក់ស្តែងកូនក្តីខ្លួនគ្រាន់តែមានវិមតិសង្ស័យ។

សំណូមពរ សូមឯកឧត្តមប្រធានក្រុមប្រឹក្សាពិចារណា បដិសេធសាលដីកាសាលាឧទ្ធរណ៍លេខ ៦៥ ក្រ II "ន" ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ និងសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ តាមមាត្រា ៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

+ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានឆ្លើយថា៖ ខ្លួនសុំឱ្យតុលាការជួយពិនិត្យឡើងវិញ ខ្លួនពុំដែលស្គាល់ជនជាប់ចោទ ២នាក់នឹងទេ ខ្លួនពុំបានប្រព្រឹត្តទេ ខ្លួនសុំឱ្យមានការលើកលែងចោទប្រកាន់ដល់ខ្លួនផង។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៣៣ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] រះ ឈ្មោះ [redacted] រដ្ឋា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ការអវត្តមានដើមបណ្តឹងរដ្ឋប្បវេណី មិនមែនជាឧបសគ្គដល់ដំណើរការដេញដោលនាពេលសវនាការពេលនេះទេ ដោយផ្អែកតាមស្មារតីមាត្រា ៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-យល់ឃើញថា ក្នុងសារណាការពាររបស់ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ហៅ ថា និងជនជាប់ចោទឈ្មោះ [redacted] រះ ហៅ រះក៏ដូចជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទលើកឡើងថា បណ្តឹងសាទុក្ខមកតុលាការកំពូលស្នើសុំតែបន្ធូរបន្ថយទណ្ឌកម្មប៉ុណ្ណោះ។ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានលើកមូលហេតុបន្ថែមថា សាលក្រម

របស់សាលាដំបូង ក៏ដូចជាសាលដីការបស់សាលាឧទ្ធរណ៍មិនបានសំអាងហេតុ ឬសំអាងហេតុខ្លះទាក់ទងនឹងការស្នើសុំបន្ថយទោសនោះដែលយុត្តិសាស្ត្ររបស់តុលាការកំពូលចាត់ទុកថា មិនបានសំអាង។ ផ្អែកតាមអង្គហេតុក្នុងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ជនជាប់ចោទមានវត្តមានក្នុងក្រុមមែនប៉ុន្តែមិនបានចូលរួមប្រព្រឹត្តទេ ជនជាប់ចោទទាំងពីរនាក់គ្រាន់តែឈរមើល មិនបានដឹងថាក្រុមគាត់ប្រព្រឹត្តបទល្មើសទេ អ្នកកាន់កាំបិតកាប់លើជនរងគ្រោះឈ្មោះ ភា ។ ព្យសនកម្មកើតមានចំពោះជនរងគ្រោះមិនធ្ងន់ធ្ងរ ជនរងគ្រោះ មិនទាមទារសំណងការខូចខាត។ ផ្អែកតាមមាត្រា ២៤ មាត្រា ៩៣ មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ អាចឲ្យតុលាការសម្រេចពីស្ថានសម្រាលទោសដល់ជនជាប់ចោទទាំងពីរនាក់បាន ។ មូលហេតុសាទុក្ខលើកឡើងខាងលើ តុលាការកំពូលពិនិត្យពិចារណាឃើញថា ការដែលសាលាឧទ្ធរណ៍ភ្នំពេញសម្រេចសេចក្តីតម្កល់សាលក្រមសាលាដំបូងរាជធានីភ្នំពេញទុកជាបានការដែលសេចក្តីសម្រេចនៃសាលក្រមសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ជនជាប់ចោទទាំងពីរនាក់ក្នុងម្នាក់១៥(ប្រាំ)ឆ្នាំ ពីបទលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឃើញថា តុលាការបានពិចារណាអំពីស្ថានសម្រាលហើយ ពីព្រោះថា ជនជាប់ចោទត្រូវតុលាការសម្រេចផ្តន្ទាទោសពីរបទល្មើស ហើយតាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ អាចឲ្យតុលាការពិចារណាសម្រេចផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារពី ៣(បី)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ ដូច្នេះការដែលជនជាប់ចោទ និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសុំបន្ថយទណ្ឌកម្មបន្ថែមទៀតពុំអាចពិចារណាបានឡើយ ។ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] វង្ហា និងឈ្មោះ [redacted] រៈ ពុំមានមូលហេតុដូចមានចែងតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ដែលគប្បីសម្រេចបដិសេធបណ្តឹងសាទុក្ខនេះចោលទាំងស្រុង ហើយសម្រេចតម្កល់សាលដីការបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ទុកជាបានការតាមមាត្រា ៤៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ហ៊ុច បានឆ្លើយដោះសារថា ខ្លួនពុំបានប្រព្រឹត្តបទល្មើសទេ ថ្ងៃកើតហេតុខ្លួនមិនដឹងទេ ហើយក៏មិនធ្លាប់ស្គាល់ក្រុមទាំងអស់នោះដែរ ។ និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានលើកមូលហេតុសាទុក្ខថា ជនជាប់ចោទឈ្មោះ [redacted] វង្ហា ហៅ ថា និងឈ្មោះ [redacted] រៈ ហៅ រៈ ជាជនដែលបានសារភាពទទួលស្គាល់កំហុស ហើយជនជាប់ចោទទាំងពីរនាក់បានឆ្លើយនៅសាលាដំបូង និងនៅសាលាឧទ្ធរណ៍បញ្ជាក់យ៉ាងច្បាស់ថា និងពុំដែលស្គាល់ឈ្មោះ [redacted] សុវណ្ណ ហើយពេលកើតហេតុពុំឃើញមានវត្តមានដែរ ។ សំអាងហេតុសាលាឧទ្ធរណ៍បានបញ្ជាក់ថា អ្នកចូលរួមប្រព្រឹត្តបទល្មើសមិនបានស្គាល់ឈ្មោះ [redacted] សុវណ្ណ ទេ ។ តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញបានសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ឆ្លើយដោះសារថាពុំបានប្រព្រឹត្តទេ ហើយបុគ្គលនេះត្រូវចាប់ខ្លួន និងឃុំខ្លួន តាមអំណាចសាលក្រម មិនបានបំពេញនីតិវិធីស៊ើបសួរឡើយ។ គួរកនដទៃទៀតពុំបានឆ្លើយដាក់បន្ទុកដល់ ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ទេ គឺមានតែបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌។ ត្រឹមតែជារបាយការណ៍របស់មន្ត្រីនគរបាលត្រូវចាត់ទុកជាវិមតិសង្ស័យ សូមក្រុមប្រឹក្សាពិចារណា ។ តំណាងមហាអយ្យការអមតុលាការកំពូល សូមតម្កល់សេចក្តីសន្និដ្ឋានដូចដែលសាលាឧទ្ធរណ៍សំអាងហេតុត្រង់ចំណុចទី៥ នៃសាលដីកាសាលាឧទ្ធរណ៍ ដែលកំណត់



Scanned with CamScanner

បានថា ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ មានវិមតិសង្ស័យនៅឡើយ ទុកសិទ្ធិជូនក្រុមប្រឹក្សាជំនុំជម្រះសម្រេចតាមច្បាប់ ។ មូលហេតុដែលលើកឡើងដោយភាគីខាងលើ តុលាការកំពូលអាចជឿជាក់បាន ពីព្រោះថា មានតែរបាយការណ៍សំយោគរបស់អធិការដ្ឋាននគរបាលយុត្តិធម៌សែនសុខ សរសេរថា ឃើញមានជនជាប់ចោទឈ្មោះ [redacted] រដ្ឋា និងជនជាប់ចោទឈ្មោះ [redacted] រះ ដែលឆ្លើយថា កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ឈ្មោះ ហ្គិច បើកម៉ូតូម៉ាកសេ១២៥ ឌុបឈ្មោះ ស្វិត ប៉ុណ្ណោះ ។ ប៉ុន្តែការឌុបនេះក៏មិនបានបញ្ជាក់នៅចំពេលទីតាំងណាមួយ ពេលណាដែរ និងក្រៅពីនេះក៏ពុំឃើញមានភស្តុតាងផ្សេងបង្ហាញពីសកម្មភាពណាមួយដែលអាចសន្និដ្ឋានបានថា ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានចូលរួមប្រព្រឹត្តបទល្មើសជាមួយនឹងចារីដទៃទៀតឡើយ ។ ផ្អែកតាមមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច និងផ្អែកតាមមាត្រា ៤៤០ នៃក្រមដដែល តុលាការកំពូលអាចប្រកាសបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ដោយពុំបង្វិលសំណុំរឿងទៅវិញបាន។

៥-យល់ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច មានមូលហេតុសាទុក្ខ ដូចមានបញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៦-យល់ឃើញថា នាពេលសវនាការនេះ តំណាងមហាអយ្យការបានធ្វើការកត់សំគាល់ដោយផ្ទាល់មាត់ថា សាលាឧទ្ធរណ៍សម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] រដ្ឋា និងឈ្មោះ [redacted] រះ ដាក់ពន្ធនាគារម្នាក់ៗកំណត់រយៈពេល ៥ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន សមស្របតាមច្បាប់ហើយ ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌទេ ។ ដូច្នេះសូមទុកសិទ្ធិជូនក្រុមប្រឹក្សាជំនុំជម្រះសម្រេចតាមច្បាប់ ។ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល ក្រុមប្រឹក្សាជំនុំជម្រះឯកភាពដោយពុំលើកយកមកសំអាងហេតុជាថ្មីម្តងទៀតទេ ។

៧-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៦៥ ក្រII "ន" ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីត្រឹមត្រូវតាមច្បាប់ខ្លះ និងខុសច្បាប់ខ្លះ។

## ហេតុដូច្នេះ

## សម្រេច

១-ទទួលបណ្តឹងសាទុក្ខលេខ ៣៣៣ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច ហើយបដិសេធបណ្តឹងសាទុក្ខលេខ ៣៣៣ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] រះ ហៅ រះ ឈ្មោះ [redacted] រដ្ឋា ហៅ ថា ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៦៥ ក្រII"ន" ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ លើកលែងតែសេចក្តីសម្រេចតម្កល់សេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ ១៥៧៥ "ច១" ក្រ១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ ត្រង់ចំណុច ៥.១ របស់សាលាដំបូងរាជធានីភ្នំពេញត្រូវបដិសេធចោល



Scanned with CamScanner

ហើយសម្រេចជាថ្មីដោយបង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ហ៊ិច រួចខ្លួនពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ និងប្រកាសនៅសាលសវនាការជាសាធារណៈនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាប្រធាន |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកស្រី | [redacted] | ជាក្រឡាបញ្ជី |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃចន្ទ ២រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ថ្ងៃចន្ទ ២រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner